# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសពត៌មាន</u>

# អូស្ត្រាលីទទួលរៀបចំប្រារព្ធពិធីបង្ហាញសមត្ថភាពទេពកោសល្យ

នាថ្ងៃទី២៩ ខែវិច្ឆិកា មានគណៈប្រតិភូក្នុងកិច្ចប្រជុំរដ្ឋភាគីលើកទី១១ នៃអនុសញ្ញាហាមឃាត់គ្រាប់មីនប្រឆាំងនឹងមនុស្សជាតិ ចំនួនរាប់រយនាក់បានចូលរួមក្នុងពិធីមួយដែលរៀបចំដោយប្រទេសអូស្ត្រាលីដើម្បីប្រារពពិធីសិល្បៈនិងវប្បធម៌ចូលរួម នៅសណ្ឋាគារកាំបូឌីយ៉ាណា។ ពិធីនេះមិនមែនត្រឹមតែជាការជប់លៀងគណៈប្រតិភូប៉ុណ្ណោះទេ។

វាមានបង្ហាញនូវការសំដែង និងការតាំងពិពណ៌របស់ក្រុមជនជាតិខ្មែរផ្សេងៗ រួមមាន ជនពិការ អ្នកសិល្បៈ ល្ខោន សៀក តន្ត្រី និងសិប្បកម្មនានា។ ការផ្តួចផ្តើមនៃពិធីនេះ ត្រូវបានធ្វើឡើងដោយសហការជាមួយក្រុមអ្នកសិល្បៈចូលរួមនៅក្នុងប្រទេសកម្ពុជា ដែលមានចំណាប់អារម្មណ៍ក្នុងឱកាសស្វែងរកលទ្ធភាពដើម្បីសហការរវាងគ្នានិងគ្នា ព្រមទាំងជាមួយនិងគណៈប្រតិភូអន្តរ-ជាតិដែលអញ្ជើញចូលរួមក្នុង កិច្ចប្រជុំរដ្ឋភាគីលើកទី១១ នៃអនុសញ្ញាហាមឃាត់គ្រាប់មីនប្រឆាំងនឹងមនុស្សជាតិ ដែលកំពុងដំណើរការនៅវិមានសន្តិភាព នារាជធានីភ្នំពេញ។

នៅក្នុងសុន្ទរកថាបើករបស់លោកជំទាវ លោកជំទាវ **ផេននី រីឆាដស៍** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា «ប្រជាជនអូស្ត្រាលីជឿជាក់លើការដើរឆ្ពោះទៅមុខដោយស្មើភាពទាំងអស់គ្នា ហើយនេះគឺជាមូលដ្ឋាននៃយុទ្ធសាស្ត្ររបស់រដ្ឋា-ភិបាលអូស្ត្រាលី ‘ការអភិវឌ្ឍន៍ដើម្បីទាំងអស់គ្នា’ ដែលមានគោលបំណងធានាថាជនពិការត្រូវបានចូលរួមនិងទទួលប្រយោជន៍ពីគម្រោងផ្តល់ជំនួយដោយស្មើភាពជាមួយអ្នកផ្សេងទៀត។»

ពិធីនេះបង្ហាញនូវវិធីសាស្ត្រតាមរយៈសិល្បៈ និងវប្បធម៌ ដែលបង្ហាញនូវគោលនយោបាយចូលរួមទាំងអស់គ្នា ពោលគឺបង្ហាញនូវការធ្វើការរួមគ្នារវាងមនុស្សធម្មតា និងជនពិការនៅក្នុងការប្រារពពិធីសម្តែងទេពកោសល្យ។ អង្គការអេពិចអាត (Epic Arts) ក្រុមអារ៉ូប៉ា (Arrupe Group) និងអង្គការគ្រួសារថ្មី បានសម្តែងនូវតន្ត្រី របាំ ល្ខោន ល្ខោនស្បែក និងសៀកខ្មែរ ទាំងលក្ខណៈប្រពៃណី និងបែបសម័យទំនើប។ វិចិត្រករ និងអ្នកសូនរូបបានធ្វើការដាក់តាំងការងាររបស់ពួកគេនៅតាមរោងជាង

តូចៗសម្រាប់បង្ហាញដល់គណៈប្រតិភូដែលមានចំណាប់អារម្មណ៍លើការងារពួកគេ។ ចំណែកឯសមាជិក១៥រូបទៀតនៃសមាគមសិប្បកម្មកម្ពុជា បានដាក់តាំងពិពណ៌ និងលក់នូវផលិតផលសិប្បកម្មរបស់ពួកគេ ជូនដល់ភ្ញៀវអន្តរជាតិ ក៏ដូចជាពន្យល់ដល់ភ្ញៀវនូវគោលគំនិតបង្កប់ក្នុងកិច្ចការរបស់ពួកគេ។

មានប្រសាសន៍ក្នុងពិធីនេះដែរ ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា បានពន្យល់ថា «សិល្បៈ និងវប្បធម៌ចូលរួម គឺជាផ្នែកមួយដ៏សំខាន់ក្នុងការអភិវឌ្ឍន៍ការចូលរួមរបស់ជនពិការ ព្រោះវាអាចផ្តល់នូវឱកាសនានាសំរាប់ជនពិការ ដើម្បីសម្រេចបាននូវសក្តានុពលរបស់ពួកគេ និងចូលរួមក្នុងជីវភាពសង្គមនិងសេដ្ឋកិច្ចរបស់សហគមន៍ពួកគេ។»

រដ្ឋាភិបាលអូស្ត្រាលី ជឿជាក់ថាការអភិវឌ្ឍន៍នឹងសម្រេចទៅបានប្រកបដោយប្រសិទ្ធភាពដរាបណាមានការចូលរួមរបស់ជនពិការនៅក្នុងដំណើរការប្រកបដោយអត្ថន័យមួយនៅក្នុងការធ្វើផែនការនិងការប្រតិបត្តិកម្មវិធីអភិវឌ្ឍន៍។ ប្រជាជនទាំងអស់មានសិទ្ធស្មើគ្នា និងត្រូវទទួលបាននូវការគោរពក្នុងកម្រិតដូចគ្នា។ ជាអកុសល មានប្រជាជនមួយចំនួន ដែលពុំទាន់ទទួលបាននូវភាពស្មើគ្នានេះ ជាឧទាហរណ៍ ជនពិការនៅតែជាជនដែលងាយរងគ្រោះ និងមានភាពរងគ្រោះខ្លាំងជាងគេបំផុតនៅក្នុងសហគមន៍។ នេះ គឺដោយសារពួកគេជួបប្រទះនូវឧបសគ្គក្នុងការទទួលបាននូវសេវាកម្ម និងការចូលរួមនៅក្នុងសេចក្តីសម្រេចចិត្ត។ អូស្ត្រាលីមានសេចក្តីរីករាយនឹងចូលរួមជួយគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាល និងក្រុមសហគមន៍នានានៅទូទាំងប្រទេសកម្ពុជា ដែលកំពុងបំពេញកិច្ចការដើម្បីលើកកម្ពស់ជីវភាពរបស់ជនពិការ។


**ទំនាក់ទំនងពត៌មានៈ**

**លោក ដេវ ហ្កាចដ៍ អ្នកនាំពាក្យប្រចាំស្ថានទូតអូស្ត្រាលី**

**លេខទូរស័ព្ទ 023 213 470**

**ស្ថានទូតអូស្ត្រាលី ភ្នំពេញ**


**ថ្ងៃទី29 ខែវិច្ឆិកា ឆ្នាំ2011**